**ឯកសារសង្ខេប**

គណៈកម្មការទី២ ព្រឹទ្ធសភា ទទួលបន្ទុកសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម

# "សេចក្តីព្រាងច្បាប់ស្តីពីការធានារ៉ាប់រង"

អ្នកស្រាវជ្រាវ៖ *សុទ្ធ សាង៍បុណ្យ*

ខែមិថុនា ឆ្នាំ២០១៤

**វិទ្យាស្ថានសភាកម្ពុជា**

# មាតិកា

សេចក្តីផ្តើមៈ .... 3

1. តើសេចក្តីព្រាងច្បាប់នេះមានទម្រង់បែបណា? .... 3

2. តើសេចក្តីព្រាងច្បាប់នេះមានគោលបំណង គោលដៅ និងវិសាលភាពបែបណា? .... 3

3. តើមានគំនិតចម្បង និងចំណុចណាខ្លះដែលត្រូវបានកែសម្រួលនៅក្នុងច្បាប់ជាធរមាន? .... 4

4. តើមានគំនិតថ្មីៗអ្វីខ្លះដែលបានបន្ថែមនៅក្នុងសេចក្តីព្រាងច្បាប់ថ្មីនេះ? .... 4

5. ហេតុអ្វីបានជាបញ្ចូលនូវគំនិត/ចំនុចថ្មីៗនៅក្នុងសេចក្តីព្រាងច្បាប់ថ្មី? .... 6

6. តើមានផលប៉ះពាល់/ការប្រែប្រួលអ្វីខ្លះប្រសិនបើសេចក្តីព្រាងច្បាប់ថ្មីនេះត្រូវបានអនុម័ត? .... 7

7. តើកម្ពុជាត្រូវធ្វើអ្វីខ្លះប្រសិនបើសេចក្តីព្រាងច្បាប់ថ្មីត្រូវបានអនុម័ត? .... 7

**សេចក្ដីផ្ដើមៈ**

ដើម្បីឆ្លើយតបទៅនឹងសំណើរបស់គណៈកម្មការទី២ ទទួលបន្ទុកសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម នៃព្រឹទ្ធសភា កាលពីថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៤ ឯកសារសង្ខេប ស្ដីពី សេចក្ដីព្រាងច្បាប់ស្ដីពីការធានារ៉ាប់រងនេះត្រូវបានរៀបចំឡើងជំនួសឲ្យការស្រាវជ្រាវពិស្ដារមួយ។ ដោយពេលវេលាខ្លីឯកសារនេះនឹងផ្ដោតលើគំនិតចម្បងនិងលក្ខណៈពិសេសនៃសេចក្ដីព្រាងច្បាប់នេះ ព្រមទាំងធ្វើការប្រៀបធៀបសង្ខេបរវាង "ច្បាប់ស្ដីពីការធានារ៉ាប់រងជាធរមានឆ្នាំ២០០០" ទៅនឹង "សេចក្ដីព្រាងច្បាប់ស្ដីពីការធានារ៉ាប់រងថ្មីឆ្នាំ២០១៤"។

ដើម្បីយល់ដឹងស្ដីពីគំនិតចម្បង និងលក្ខណៈពិសេសនៃសេចក្ដីព្រាងច្បាប់ថ្មី ឯកសារនេះនឹងផ្ដោតលើបញ្ហាដូចខាងក្រោមនេះៈ

1. **តើសេចក្ដីព្រាងច្បាប់នេះមានទម្រង់បែបណា?**

សេចក្ដីព្រាងច្បាប់ស្ដីពីការធានារ៉ាប់រងថ្មីនេះ មានទំរង់ស្របទៅតាមបទដ្ឋាននៃការតាក់តែងច្បាប់ ដែលក្នុងសេចក្ដីព្រាងច្បាប់នេះមានចែងអំពីបទបញ្ញត្តិទូទៅ បទបញ្ញត្តិគ្រប់គ្រង ទោសបញ្ញត្តិ និងអវសានប្បញ្ញត្តិ។ លើសពីនេះ សេចក្ដីព្រាងច្បាប់ថ្មីនេះបានបន្ថែមនូវសទ្ទានុក្រមដែលពន្យល់ពាក្យបច្ចេកទេស ធ្វើឲ្យអ្នកអនុវត្តកាន់តែងាយយល់ និងមានភាពងាយស្រួលក្នុងការអនុវត្តន៍[1]។ នៅក្នុងច្បាប់ស្ដីពីការធានារ៉ាប់រងជាធរមានឆ្នាំ២០០០ មិនមានការកំណត់និយមន័យពាក្យបច្ចេកទេសដែលពាក់ព័ន្ធបែបនេះទេ។ សេចក្ដីព្រាងច្បាប់ថ្មីនេះមាន ១៤ជំពូក និង ១១៤មាត្រា ដែលពិស្ដារជាងច្បាប់ជាធរមានឆ្នាំ២០០០ ដែលមានតែ៨ជំពូក និង៥៦មាត្រាប៉ុណ្ណោះ។

2. **តើសេចក្ដីព្រាងច្បាប់នេះមានគោលបំណង គោលដៅ និងវិសាលភាពបែបណា?**

ច្បាប់ជាធរមានមិនមានគោលបំណងច្បាស់លាស់ដូចសេចក្ដីព្រាងច្បាប់ថ្មីទេ[2]។ សេចក្ដីព្រាងច្បាប់ថ្មីនេះមានគោលបំណង គោលដៅ និងវិសាលភាពធំទូលាយ និងច្បាស់លាស់ជាងច្បាប់ជាធរមាន។ ឧទាហរណ៍ៈ វិសាលភាពនៅក្នុងច្បាប់ជាធរមានមានលក្ខណៈទូលំទូលាយពេ[3] ប៉ុន្តែនៅក្នុងសេចក្ដីព្រាងច្បាប់ថ្មីមានលក្ខណៈច្បាស់លាស់ជាង ដោយគ្របដណ្ដប់លើការធានារ៉ាប់រងអាយុជីវិត និងការធានារ៉ាប់រងខ្នាតតូច បន្ថែមលើការធានារ៉ាប់រងទូទៅដែលមានភាពមិនច្បាស់លាស់នៅក្នុងច្បាប់ចាស់។ សេចក្ដីព្រាងច្បាប់ថ្មីនេះក៏បានបើកចំហរនូវភាពបទបែនសម្រាប់បញ្ញត្តករតាមរយៈការចេញអនុក្រឹត្យ ឬប្រកាស បន្ថែមលើច្បាប់ដែលមានស្រាប់ដើម្បីធ្វើអន្តរាគមន៍នៅពេលឧស្សាហកម្មនេះមានស្ថានភាពមិនល្អ។

---

[1] មាត្រា៤នៃសេចក្ដីព្រាងច្បាប់ថ្មីស្ដីពីការធានារ៉ាប់រង បានកំណត់និយមន័យពាក្យបច្ចេកទេសដែលពាក់ព័ន្ធចំនួន១៩ ដែលនៅក្នុងច្បាប់ចាស់មិនបានពន្យល់ទេ

[2] មាត្រា១នៃសេចក្ដីព្រាងច្បាប់ថ្មីចែងគោលបំណង៤ច្បាស់លាស់គឺ ការអភិវឌ្ឍន៍ប្រកបដោយចីរភាពនៃវិស័យធានារ៉ាប់រង ផលប្រយោជន៍សាធារណៈនិងទំនុកចិត្តដល់សេវាធានារ៉ាប់រង សង្គតភាពជាមួយគោលការគ្រឹះធានារ៉ាប់រងអន្តរជាតិ និងធានាផលប្រយោជន៍របស់រូបវន្តនិងនីតិបុគ្គលដែលជាអ្នកត្រូវបានធាននារ៉ាប់រង។

[3] មាត្រា២នៃច្បាប់ស្ដីពីការធានារ៉ាប់រងចាស់មានន័យទូលំទូលាយ និងមិនស៊ីជំរៅទេព្រោះវិសាលភាពរបស់វាអនុវត្តចំពោះសកម្មភាពធានារ៉ាប់រងទាំងអស់ដែលប្រតិបត្តិការនៅក្នុងព្រះរាជាណាចក្រកម្ពុជា

**3. តើមានគំនិតចម្បង និងចំណុចណាខ្លះដែលត្រូវបានកែសម្រួលនៅក្នុងច្បាប់ជាធរមាន?**

មានការកែសម្រួលមួយចំនួនទៅលើច្បាប់ស្តីពីការធានារ៉ាប់រងឆ្នាំ២០០០ ដូចជា៖

- ✓ មាត្រា៥ នៃសេចក្តីព្រាងច្បាប់ថ្មី ផ្តល់សិទ្ធិឲ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុចេញបទប្បញ្ញត្តិគ្រប់គ្រង និងត្រួតពិនិត្យលើការធ្វើអាជីវកម្មធានារ៉ាប់រង ប៉ុន្តែនៅក្នុងមាត្រា៧ច្បាប់ឆ្នាំ២០០០ ក្រសួងមានសិទ្ធិត្រឹមតែគ្រប់គ្រង និងត្រួតពិនិត្យលើអាជីវកម្មប៉ុណ្ណោះ។
- ✓ មាត្រា៦ នៃសេចក្តីព្រាងច្បាប់ថ្មី បានបន្ថែមសមត្ថកិច្ចដល់ក្រសួងសេដ្ឋកិច្ចនិង ហិរញ្ញវត្ថុក្នុងការបង្កើត និងគ្រប់គ្រងមូលនិធិអភិវឌ្ឍវិស័យធានារ៉ាប់រង និងលើកកម្ពស់ការផ្សព្វផ្សាយអំពីអត្ថប្រយោជន៍នៃការធានារ៉ាប់រងដល់សាធារណៈជន ដែលចំនុចនេះមិនមានក្នុងច្បាប់ឆ្នាំ២០០០ទេ។
- ✓ ក្នុងជំពូកទី៤ ក្នុងមាត្រា៣៣នៃសេចក្តីព្រាងច្បាប់ថ្មីដែលចែងអំពីការធានារ៉ាប់រងជាកាតព្វកិច្ច បានដាក់កាតព្វកិច្ចឲ្យរូបវន្តបុគ្គល និងនីតិបុគ្គលជាម្ចាស់យានយន្តដែលប្រកបអាជីវកម្មទាំងអស់ក្នុងព្រះរាជាណាចក្រកម្ពុជាត្រូវមានការធានារ៉ាប់រងពីក្រុមហ៊ុនធានារ៉ាប់រង ដែលនៅក្នុងមាត្រា៣៦ នៃច្បាប់ឆ្នាំ២០០០ តម្រូវឲ្យតែយានយន្តដែលប្រកបអាជីវកម្មយកកម្រៃតាមផ្លូវគោកប៉ុណ្ណោះដែលត្រូវជាប់កាតព្វកិច្ច។
- ✓ ក្នុងជំពូកទី២ ផ្នែកទី២ និងផ្នែកទី៣ នៃសេចក្តីព្រាងច្បាប់ថ្មីបានឲ្យនិយមន័យ និងបែងចែកប្រភេទធានារ៉ាប់រងជា២ប្រភេទច្បាស់លាស់គឺ ការធានារ៉ាប់រងទូទៅ និងការធានារ៉ាប់រងអាយុជីវិត ដែលខុសពីច្បាប់ឆ្នាំ២០០០ដែលកំណត់ថា ប្រភេទនៃការធានារ៉ាប់រងមានតែការធានារ៉ាប់រងទូទៅ ដែលសំដៅលើការធានារ៉ាប់រងទ្រព្យសម្បត្តិ និងការធានារ៉ាប់រងបុគ្គល រួមមានការធានារ៉ាប់រងអាយុជីវិត និងការធានារ៉ាប់រងគ្រោះថ្នាក់ដល់រូបរាងកាយ ហើយការអោយនិយមន័យក្នុងច្បាប់ឆ្នាំ២០០០ មិនទាន់មានភាពច្បាស់លាស់នៅ ឡើយទេ។
- ✓ ការឲ្យនិយមន័យ និងការបែងចែកប្រភេទធានារ៉ាប់រងដកចេញជាពីរប្រភេទច្បាស់លាស់គឺ ការពង្រីកវិសាលភាពក្នុងការធ្វើអាជីវកម្មធានារ៉ាប់រងឲ្យស្របតាមគោលការណ៍របស់សមាគមបញ្ញត្តិករធានារ៉ាប់រងអន្តរជាតិ (IAIS) និងការធ្វើឲ្យស្របតាមទីផ្សារក្នុងតំបន់ និងលើពិភពលោក។

**4. តើមានគំនិតថ្មីៗអ្វីខ្លះដែលបានបន្ថែមនៅក្នុងសេចក្តីព្រាងច្បាប់ថ្មីនេះ?**

មានគំនិតថ្មីៗមួយចំនួនដែលបានបញ្ចូលនៅក្នុងសេចក្តីព្រាងច្បាប់ថ្មីនេះ ដូចជា៖

- ✓ ការធានារ៉ាប់រងខ្នាតតូច
  - ការធានារ៉ាប់រងខ្នាតតូចពុំមានចែងនៅក្នុងច្បាប់ឆ្នាំ២០០០ទេ ប៉ុន្តែវាមានចែងនៅក្នុងសេចក្តីព្រាងច្បាប់ថ្មីក្នុងមាត្រា៣៩ និងមាត្រា៤០ ក្នុងគោលបំណងផ្តល់កិច្ចសន្យាធានារ៉ាប់រងដល់ប្រជាពលរដ្ឋដែលមានចំណូលតិច ដែលការធានារ៉ាប់រងខ្នាតតូចនេះនឹងត្រូវកំណត់ដោយអនុក្រឹត្យ។

- ✓ នីតិវិធីជម្រះបញ្ជី
    - ○ ក្នុងជំពូកទី៨ នៃសេចក្តីព្រាងច្បាប់ថ្មីបានចែងអំពីការជម្រះបញ្ជីរំលាយក្រុមហ៊ុន និងនីតិវិធីជម្រះបញ្ជី ដែលចំណុចនេះមិនមានចែងច្បាស់លាស់ទេនៅក្នុងច្បាប់ឆ្នាំ២០០០។ ច្បាប់ស្តីពីការក្ស័យធនឆ្នាំ២០០៧ មាត្រា៦ក៏មិនបានចែងអំពីការជម្រះបញ្ជីរំលាយក្រុមហ៊ុនធានារ៉ាប់រងឡើយ ដូច្នេះហើយទើបនៅក្នុងសេចក្តីព្រាងច្បាប់ថ្មីនេះមានចែងលំអិតពីដំណើរការ និងនីតិវិធីច្បាស់លាស់អំពីការជម្រះបញ្ជីរំលាយក្រុមហ៊ុន ដែលជាប្រការល្អមួយដើម្បីការពារផលប្រយោជន៍ស្របច្បាប់របស់ម្ចាស់ប័ណ្ណសន្យារ៉ាប់រង (ការពារអ្នកប្រើប្រាស់/ម្ចាស់បំណុល ការពារអ្នកវិនិយោគ និងសាធារណជន)។
    - ○ ការជម្រះបញ្ជីក្រុមហ៊ុននៅក្នុងច្បាប់ថ្មីនេះមាន៤ផ្នែកគឺៈ
        - ▪ ផ្នែកទី១ៈ ការជម្រះបញ្ជីរំលាយក្រុមហ៊ុនដោយស្ម័គ្រចិត្ត (មាត្រា៥៩-មាត្រា៧២)
        - ▪ ផ្នែកទី២ៈ អភិបាលកិច្ចបណ្តោះអាសន្ន (មាត្រា៧៣-មាត្រា៨០)
        - ▪ ផ្នែកទី៣ៈ ការជម្រះបញ្ជីតាមផ្លូវតុលាការ (មាត្រា៨១-មាត្រា៨៤)
        - ▪ ផ្នែកទី៤ៈ បទប្បញ្ញត្តិរួមនៃការជម្រះបញ្ជី (មាត្រា៨៥-មាត្រា៨៨)
- ✓ ការផ្សះផ្សាវិវាទ
    - ○ នៅក្នុងច្បាប់ធានារ៉ាប់រងឆ្នាំ២០០០មិនមានចែងអំពីការផ្សះផ្សាវិវាទទេ។ ដូច្នេះ នៅពេលមានវិវាទកើតឡើង ភាគីវិវាទអាចប្រើយន្តការតុលាការដែលអាចជាបន្ទុកបន្ថែមទៀតសម្រាប់តុលាការ អាចត្រូវចំណាយពេលវេលាយូរ និងថវិកាច្រើនក្នុងការដោះស្រាយវិវាទ។ ប្រការនេះអាចធ្វើឲ្យប្រតិបត្តិករ និងសាធារណជនក្នុងវិស័យធានារ៉ាប់រងមានការលំបាក និងបាត់ទំនុកចិត្តក្នុងការវិនិយោគលើវិស័យនេះ។
    - ○ ដើម្បីដោះស្រាយបញ្ហាខាងលើ សេចក្តីព្រាងច្បាប់ថ្មីបានចែងអំពីការផ្សះផ្សាវិវាទនៅក្នុងជំពូកទី៩ ចាប់ពីមាត្រា៨៩ ដល់មាត្រា៩៣ ក្នុងគោលបំណងសម្រួលដល់ការដោះស្រាយរាល់វិវាទដែលពាក់ព័ន្ធនឹងវិស័យធានារ៉ាប់រង។ គំនិតថ្មីពាក់ព័ន្ធទៅនឹងការផ្សះផ្សាវិវាទនៅក្នុងសេចក្តីព្រាងច្បាប់នេះមានដូចជាៈ
        - ▪ គ្រប់វិវាទពាក់ព័ន្ធនឹងអាជីវកម្មធានារ៉ាប់រង ភាគីអាចនាំយកទៅផ្សះផ្សានៅក្រសួងមុននឹងប្តឹងតទៅវេទិកាមជ្ឈត្តកម្ម ឬតុលាការ លើកលែងតែរឿងព្រហ្មទណ្ឌ។
        - ▪ ក្រសួងត្រូវធ្វើកំណត់ហេតុអំពីលទ្ធផលនៃការផ្សះផ្សាវិវាទ ដោយមានចុះហត្ថលេខាដោយគូភាគីផងដែរ។
        - ▪ នីតិវិធីផ្សះផ្សាវិវាទកំណត់ដោយអនុក្រឹត្យ
        - ▪ ករណីគ្មានការសះជានឹងគ្នា ភាគីអាចប្តឹងទៅវេទិកាមជ្ឈត្តកម្ម ឬតុលាការ ក្នុងរយៈពេល៩០ថ្ងៃ គិតពីថ្ងៃពុំមានការសះជា។
- ✓ អធិការកិច្ចធានារ៉ាប់រង
    - ○ ក្នុងជំពូក៧ ចាប់ពីមាត្រា៥១ ដល់មាត្រា៥៨ នៃសេចក្តីព្រាងច្បាប់ថ្មីនេះ បានចែងអំពីអធិការកិច្ចធានារ៉ាប់រង។ ដោយវិស័យធានារ៉ាប់រងមានប្រតិបត្តិការស្មុគស្មាញទាំងក្នុងដំណើរការ

អាជីវកម្ម និងទាំងក្នុងការគ្រប់គ្រង ប៉ុន្តែដោយសារវិស័យនេះគឺជាវិស័យចម្បងមួយក្នុងវិស័យហិរញ្ញវត្ថុ ដូច្នេះការគ្រប់គ្រង និងការធ្វើអធិការកិច្ច ត្រូវឋិតនៅក្រោមការគ្រប់គ្រង និងចាត់ចែងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ អ្នកដែលមាននីតិសម្បទាពិនិត្យ និងចាត់ការរាល់បទល្មើសនានាទាក់ទងនឹងវិស័យធានារ៉ាប់រង គឺជាមន្ត្រីអធិការកិច្ចធានារ៉ាប់រង និងមន្ត្រីនគរបាលយុត្តិធម៌។

- ○ មន្ត្រីអធិការកិច្ចធានារ៉ាប់រងត្រូវបានផ្តល់សិទ្ធិអំណាចគ្រប់គ្រាន់ និងទូលំទូលាយក្នុងការដោះស្រាយសំណុំរឿងដោយទទួលបាននីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌តាមក្រមនីតិវិធីព្រហ្មទណ្ឌ។

✓ ទណ្ឌកម្មវិន័យ

- ○ សេចក្តីព្រាងច្បាប់ថ្មីស្តីពីការធានារ៉ាប់រងបានចែងពិស្តារអំពីការដាក់ទណ្ឌកម្ម ដែលទណ្ឌកម្មទាំងនោះរួមមានទណ្ឌកម្មខាងវិន័យ [4] និងការផាកពិន័យផ្នែកហិរញ្ញវត្ថុ ព្រមទាំងការផ្តន្ទាទោសដាក់ពន្ធនាគារផងដែរ [5] ។ ដោយឡែក នៅក្នុងច្បាប់ឆ្នាំ២០០០ ពុំមានចែងអំពីទណ្ឌកម្មខាង វិន័យដាច់ដោយឡែកទេ ផ្ទុយទៅវិញការផាកពិន័យផ្នែកហិរញ្ញវត្ថុ និងទណ្ឌកម្មខាងវិន័យត្រូវ ធ្វើឡើងនៅពេលជាមួយគ្នាក្នុងករណីដែលប្រតិបត្តិករប្រព្រឹត្តិល្មើសនឹងមាត្រា៤៤ ឬមាត្រា៤៨ នៃច្បាប់នោះ។

✓ ពិន័យអន្តរកាល

- ○ នៅក្នុងមាត្រា១០៩ នៃសេចក្តីព្រាងច្បាប់ថ្មីបានផ្តល់សិទ្ធិឲ្យរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុចេញប្រកាសកំណត់ និងធ្វើការពិន័យអន្តរកាលចំពោះគ្រឹះស្ថានធានារ៉ាប់រងទាំងឡាយណាដែលមិនគោរពតាមការណែនាំរបស់ក្រសួង ហើយសិទ្ធិ និងការពិន័យអន្តរការណ៍បែបនេះពុំមានចែងទេនៅក្នុងច្បាប់ឆ្នាំ២០០០ទេ។

## 5. ហេតុអ្វីបានជាបញ្ចូលនូវគំនិត/ចំនុចថ្មីៗនៅក្នុងសេចក្តីព្រាងច្បាប់ថ្មី?

មានហេតុផលមួយចំនួនក្នុងការបញ្ចូលនូវគំនិតថ្មី និងការរៀបចំសេចក្តីព្រាងច្បាប់ថ្មីដូចខាងក្រោមនេះ៖

✓ ការធានាការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឲ្យស្របតាមគោលការណ៍របស់សមាគមបញ្ញត្តិករធានារ៉ាប់រងអន្តរជាតិ (IAIS)

✓ ការធ្វើបច្ចុប្បន្នភាព និងសុក្រឹតភាពយុទ្ធសាស្រ្តវិស័យហិរញ្ញវត្ថុឆ្នាំ២០១១-២០២០

✓ ពង្រឹងក្របខ័ណ្ឌច្បាប់ឲ្យស្របតាមទីផ្សារក្នុងតំបន់និងលើពិភពលោក

---

[4] មាត្រា៩៤ ដល់មាត្រា៩៦ នៃសេចក្តីព្រាងច្បាប់ថ្មី

[5] មាត្រា៩៧ ដល់មាត្រា១០៩ នៃសេចក្តីព្រាងច្បាប់ថ្មី

6. **តើមានផលប៉ះពាល់/ការប្រែប្រួលអ្វីខ្លះប្រសិនបើសេចក្តីព្រាងច្បាប់ថ្មីនេះត្រូវបានអនុម័ត?**

ប្រសិនបើសេចក្តីព្រាងច្បាប់ថ្មីនេះត្រូវបានអនុម័ត គឺអាចនឹងមានផលប៉ះពាល់/ការប្រែប្រួលដូចខាងក្រោម៖

- ✓ ផលចំណេញផ្នែកសេដ្ឋកិច្ច
  - ○ បង្កើនសាច់ប្រាក់សន្សំក្នុងស្រុក និងអាចយកសាច់ប្រាក់សន្សំនេះប្រើប្រាស់ និងវិនិយោគលើផ្នែកដ៏ទៃទៀតបាន
  - ○ ជួយកាត់បន្ថយចំណាយរបស់រាជរដ្ឋាភិបាលលើការថែទាំ និងព្យាបាលសុខភាពសាធារណៈ
- ✓ ផលចំណេញផ្នែកសង្គម
  - ○ ប្រជាពលរដ្ឋអាចប្រើប្រាស់ប្រាក់សន្សំសាធារណៈសម្រាប់ចំណាយលើហានិភ័យរបស់ខ្លួនពេលដែលមានគ្រោះថ្នាក់កើតឡើង
  - ○ ប្រតិបត្តិករធានារ៉ាប់រងអាចសម្រាលបន្ទុករបស់រាជរដ្ឋាភិបាលក្នុងការគ្រប់គ្រងហានិភ័យ
  - ○ ជួយសម្រាលបន្ទុករបស់តុលាការក្នុងការដោះស្រាយវិវាទផ្នែកធានារ៉ាប់រង
  - ○ ជួយលើកកម្ពស់ផ្នែកចរាចរណ៍ និងកាត់បន្ថយការកកស្ទះចរាចរណ៍ពេលមានគ្រោះថ្នាក់

7. **តើកម្ពុជាត្រូវធ្វើអ្វីខ្លះប្រសិនបើសេចក្តីព្រាងច្បាប់ថ្មីត្រូវបានអនុម័ត?**

- ✓ ប្រសិនបើសេចក្តីព្រាងច្បាប់ថ្មីនេះត្រូវបានអនុម័ត កម្ពុជាត្រូវមានកាតព្វកិច្ចមួយចំនួនដូចខាងក្រោម៖
  - ○ ត្រូវរៀបចំអនុក្រឹត្យថ្មីស្តីពីការធានារ៉ាប់រងខ្នាតតូចឆ្លើយតបនឹងមាត្រា៤០
  - ○ ត្រូវកែសម្រួលប្រកាសពាក់ព័ន្ធចំនួន១៦
  - ○ ត្រូវរៀបចំប្រកាសថ្មីមួយចំនួនស្តីពីការធានារ៉ាប់រងអាយុជីវិត និងការធានារ៉ាប់រងខ្នាតតូច